# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧ អនក.បក

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើត គណៈកម្មការសិក្សា និងវាយតម្លៃផ្នែកសេដ្ឋកិច្ច នៃគម្រោងអភិវឌ្ឍន៍ទីក្រុងកែប

********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើ ច្បាប់ភូមិបាល
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត គណៈកម្មការសិក្សា និងវាយតម្លៃផ្នែកសេដ្ឋកិច្ច នៃគម្រោងអភិវឌ្ឍន៍ទីក្រុងកែប ដែលមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម សយ សុខា | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម រស់ រ៉េន | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៤- ឯកឧត្តម ឡុញ ហ៊ាល | អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន | សមាជិក |
| ៥- ឯកឧត្តម ហាស់ សារ៉េត | អភិបាលក្រុងកែប | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ៦- លោក ម៉ែន សុផល | ប្រធាននាយកដ្ឋាននគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- លោក យ៉ុន ហេង | អនុប្រធាននាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨- លោក ខាវ៉ាន់ វុឌ្ឍី | អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការ ទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**ប្រការ ២.-**

គណៈកម្មការសិក្សា និងវាយតម្លៃផ្នែកសេដ្ឋកិច្ច មានភារកិច្ចដូចតទៅ :

១- ធ្វើការសិក្សាលើទិដ្ឋភាពច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច និងបច្ចេកទេស នៃគម្រោងអភិវឌ្ឍន៍ទីក្រុងកែប ។

២- ដឹកនាំ និងពិនិត្យឯកសារបច្ចេកទេស ការរៀបចំប្លង់មេ ការរៀបចំកិច្ចសន្យាធុរកិច្ច ទាក់ទិននិងការបូម ដីចាក់ និងការបែងចែកឡូត៍ សំរាប់ឱ្យផ្នែកឯកជនធ្វើការអភិវឌ្ឍន៍ ។

៣- បង្កើតអនុគណៈកម្មការបច្ចេកទេសមួយ ជាជំនួយការក្នុងការរៀបចំឯកសារបច្ចេកទេស ។

៤- ធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការសិក្សា ដើម្បីសុំការសម្រេចតាមជំហាន ជាក់ស្តែង ។

**ប្រការ ៣.-**

សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មការមានសិទ្ធិ អញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតមកចូលរួមប្រជុំ តាមការចាំបាច់ ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com